**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០១ សណន

# សេចក្តីណែនាំ

## ស្តីពី

## ការសុំច្បាប់ឈប់ពិសេស
## របស់មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ
## ដែលជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

**********

អនុលោមតាមមាត្រា ៩៦ វាក្យខ័ណ្ឌទី ១ នៃច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ចែងថា " មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរៈភូមិន្ទ នគរបាលជាតិ ដែលមានបំណងឈរឈ្មោះជាបេក្ខជនជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេស យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផល នៃការបោះឆ្នោត ជាផ្លូវការ ។ "

អាស្រ័យហេតុនេះ សូមគ្រប់ក្រសួង ស្ថាប័ន ជាអាណាព្យាបាលនៃមន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរៈភូមិន្ទ នគរបាលជាតិ ដែលជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ សំរួលនឹងអនុញ្ញាតតាមសំណើសុំច្បាប់ឈប់ពិសេសរបស់សាមីខ្លួននេះ ឱ្យបានទាន់ពេលវេលាកំណត់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- កាលប្បវត្តិ-ឯកសារ